Open Budget Index 2008

**កម្ពុជា**

មិនគ្រប់គ្រាន់ ឬគ្មានតែម្តង | មានតិចតួច | មានមួយចំនួន | មានយ៉ាងច្រើន | មានយ៉ាងបរិបូណ៌

0% | 50% | 100%

# សេចក្តីសង្ខេបព័ត៌មានដែលអាចរកបានជាសាធារណៈក្នុងឯកសារថវិកាសំខាន់ៗ

ពិន្ទុរបស់កម្ពុជាលើសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាបង្ហាញថា រដ្ឋាភិបាលផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ដល់សាធារណជនអំពីសកម្មភាពថវិកា និងហិរញ្ញវត្ថុរបស់រដ្ឋាភិបាលក្នុងឆ្នាំថវិកា។ ប្រការនេះធ្វើឱ្យប្រជាពលរដ្ឋកម្ពុជាមានការលំបាកក្នុងការទាមទារឱ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះការគ្រប់គ្រងថវិកាសាធារណៈ។

សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០០៨ វាយតម្លៃទៅលើបរិមាណ និងប្រភេទព័ត៌មានដែលរដ្ឋាភិបាលផ្សព្វផ្សាយទៅកាន់សាធារណជនរបស់ខ្លួនតាមរយៈឯកសារថវិកាសំខាន់ៗទាំងប្រាំបី ដែលគប្បីចែកផ្សាយក្នុងឆ្នាំថវិកា។ ឯកសារមួយក្នុងចំណោមឯកសារសំខាន់បំផុតទាំងប្រាំបីគឺ សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល។ សេចក្តីព្រាងច្បាប់នេះមានបញ្ជាក់អំពីផែនការរបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំបន្ទាប់នូវទឹកប្រាក់ចំណាយចំពោះសំណើរសកម្មភាពនានា។ សេចក្តីព្រាងច្បាប់នេះគប្បីត្រូវបានផ្សព្វផ្សាយដល់សាធារណជន និងរដ្ឋសភាមុនពេលអនុម័ត យ៉ាងហោចណាស់បីខែមុនពេលចាប់ផ្តើមឆ្នាំថវិកាដើម្បីអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សំរាប់ការពិនិត្យ និងជជែកដេញដោលជាសាធារណៈលើសេចក្តីព្រាងច្បាប់ថវិកានោះ។

ភាពអាចរកបានជាសាធារណៈនៃឯកសារថវិកាសំខាន់ៗ និងថវិការបស់ប្រជាពលរដ្ឋ
(តាមលំដាប់នៃការរំពឹងអំពីការបញ្ចេញព័ត៌មាន)

| | | |
|---|---|---|
| របាយការណ៍បុរេថវិកា | ○ | គ្មាន |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល | ○ | គ្មាន |
| ថវិកាសំរាប់ប្រជាពលរដ្ឋ | ○ | គ្មាន |
| ថវិកាដែលបានអនុម័ត (ច្បាប់ថវិកាប្រចាំឆ្នាំ) | ● | មាន |
| របាយការណ៍នានាក្នុងឆ្នាំ | ● | មាន |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | ○ | គ្មាន |
| របាយការណ៍ដំណាច់ឆ្នាំ | ● | មាន |
| របាយការណ៍សវនកម្ម | ○ | គ្មាន |

នៅកម្ពុជាសេចក្តីព្រាងច្បាប់ថវិកាត្រូវបានផលិតសម្រាប់តែប្រើប្រាស់ផ្ទៃក្នុងប៉ុណ្ណោះ។ សេចក្តីព្រាងច្បាប់នេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយរហូតទាល់តែរដ្ឋសភា និងព្រឹទ្ធសភា អនុម័ត និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ។ ប្រការនេះមានន័យថា ប្រជាពលរដ្ឋមិនបានដឹងទិដ្ឋភាពពេញលេញនៃផែនការរបស់រដ្ឋាភិបាលក្នុងការយកពន្ធ និងក្នុងការចំណាយសម្រាប់ឆ្នាំបន្ទាប់ឡើយ។

ជាងនេះទៅទៀត មានការលំបាកក្នុងការតាមដានការចំណាយ ការងារប្រមូលចំណូល និងការខ្ចីបុលក្នុងឆ្នាំថវិកា។ កម្ពុជាបោះផ្សាយរបាយការណ៍ប្រចាំខែនៅក្នុងឆ្នាំអនុវត្តថវិកា ប៉ុន្តែមិនបញ្ចេញរបាយការណ៍ត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំឱ្យសាធារណជនដឹងឡើយ។ ការបោះផ្សាយឯកសារនេះអាចជួយពង្រឹងការទទួលខុសត្រូវសាធារណៈតាមរយៈការផ្តល់នូវព័ត៌មានទាន់ហេតុការណ៍អំពីថាតើថវិកាត្រូវបានអនុវត្តក្នុងឆ្នាំថវិកាយ៉ាងដូចម្តេច។

ទន្ទឹមនឹងនេះក៏មានការលំបាកក្នុងការវាយតម្លៃលទ្ធផលអនុវត្តន៍ថវិកានៅកម្ពុជាផងដែរ នៅពេលណាដែលឆ្នាំថវិកាចប់ហើយនោះ។ មានការផលិតរបាយការណ៍ដំណាច់ឆ្នាំ ដែលអនុញ្ញាតឱ្យធ្វើការប្រៀបធៀបរវាងតួលេខដែលបានគ្រោងក្នុងច្បាប់ថវិកា និង តួលេខដែលបានចំណាយ និងដែលបានប្រមូលជាក់ស្តែង ប៉ុន្តែគ្មានការពន្យល់អំពីមូលហេតុនៃភាពខុសគ្នារវាងគម្រោង និងការ

អនុវត្តជាក់ស្តែងទាំងនេះឡើយ ។ ក្រៅពីនេះកម្ពុជាក៏មិនបានផ្សព្វផ្សាយរបាយការណ៍សវនកម្មដែលផលិតដោយអាជ្ញាធរសវនកម្មជាតិជាសាធារណៈ  ហើយក៏មិនផ្តល់ព័ត៌មានណាមួយដែលបង្ហាញថាតើអនុសាសន៍នៅក្នុងរបាយការណ៍សវនកម្មត្រូវបានរដ្ឋាភិបាលអនុវត្តដោយជោគជ័យ ឬយ៉ាងណានោះទេ ។

លទ្ធភាពទទួលបានព័ត៌មានពិស្តារស្តីពីការអនុវត្តថវិកា  ដែលចាំបាច់សម្រាប់ស្វែងយល់អំពីភាពជឿនលឿនរបស់រដ្ឋាភិបាលក្នុងការអនុវត្តគម្រោង ឬសកម្មភាពជាក់លាក់ណាមួយនៅតែមានកំរិតនៅឡើយ ។ កម្ពុជានៅមិនទាន់បានរៀបចំបញ្ចូលសិទ្ធិទទួលបានព័ត៌មានពីរដ្ឋាភិបាលទៅជាច្បាប់នៅឡើយទេ ។

## ការចូលរួមរបស់សាធារណជន  និងស្ថាប័នដែលមានការទទួលខុសត្រូវ

លើសពីការលើកកំពស់លទ្ធភាពទទួលបានឯកសារថវិកាសំខាន់ៗ  នៅមានវិធីដ៏ទៃទៀត  ដែលអាចធ្វើឱ្យដំណើរការថវិការបស់កម្ពុជាកាន់តែមានលក្ខណៈបើកចំហបន្ថែមទៀត ។

គេអាចបង្កើនឱកាសសម្រាប់ឱ្យប្រជាពលរដ្ឋចូលរួមក្នុងការជជែកដេញដោលអំពីបញ្ហាថវិកា ឧទាហរណ៍ រដ្ឋសភាជាតិមិនបានធ្វើសវនាការថវិកានៅវិមានរដ្ឋសភាដែលសាធារណជនអាចចូលរួមបានទោះបីជាតំណាងរដ្ឋសភា  និងព្រឹទ្ធសភាបានចូលរួមយ៉ាងសកម្មនៅក្នុងសិក្ខាសាលាស្តីពីការវិភាគសេចក្តីព្រាងច្បាប់ថវិកានៅចុងឆ្នាំ ២០០៧ និង ២០០៨ ក៏ដោយ ។

ជាងនេះទៅទៀត  ទោះបីជាអាជ្ញាធរសវនកម្មជាតិរបស់កម្ពុជា  មានឆន្ទានុសិទ្ធិក្នុងការសម្រេចចិត្តធ្វើសវនកម្មណាមួយក៏ស្ថាប័ននេះពុំមានថវិកាគ្រប់គ្រាន់សម្រាប់បំពេញអាណត្តិការងាររបស់ខ្លួនដែរ ។ ក្រៅពីនេះ អាជ្ញាធរសវនកម្មជាតិពុំមានយន្តការផ្លូវការណាមួយក្នុងការទំនាក់ទំនងជាមួយសាធារណជនឡើយ ។

សន្ទស្សន៍ស្តីពីការផ្សព្វផ្សាយព័ត៌មានថវិកាវាយតម្លៃទៅលើបរិមាណ  និងប្រភេទព័ត៌មានដែលមាននៅក្នុងឯកសារថវិកាជាតិសម្រាប់សាធារណជន ។ ការដាក់ពិន្ទុលើតម្លាភាពរបស់ប្រទេសមួយទៅក្នុងក្រុមប្រទេសដែលបានអនុវត្តដំណើរការថវិកាត្រូវបានកំណត់ដោយការគណនារកមធ្យមភាគនៃចម្លើយ  ដែលបានឆ្លើយតបនឹងសំណួរចំនួន ៩១  នៅលើកម្រងសំណួរស្តីពីការផ្សព្វផ្សាយព័ត៌មានថវិកា និងទាក់ទងនឹងព័ត៌មានដែលមាននៅក្នុងឯកសារថវិកាសំខាន់ៗទាំងប្រាំបីដែលប្រទេសទាំងឡាយគប្បីផ្សព្វផ្សាយឱ្យសាធារណជន ។  សូមមើលរូបភាពនៅទំព័រទី  ៣  ដែលបង្ហាញពីចំណាត់ថ្នាក់កម្ពុជាដែលបានពិន្ទុ  ១១%  ក្នុងក្រុមទី  ៥ នៃប្រទេសដែលបានផ្សព្វផ្សាយព័ត៌មានថវិកាមិនគ្រប់គ្រាន់ ឬគ្មានផ្សព្វផ្សាយតែម្តងក្នុងចំណោមប្រទេសទាំង៨៥ ។

ចំពោះអត្ថន័យនៃពាក្យថា "ព័ត៌មានដែលអាចរកបានជាសាធារណៈ" ភាពជាដៃគូនៃថវិកាអន្តរជាតិ ( IBP ) បានកំណត់និយមន័យសំដៅលើឯកសារដែលចេញដោយអាជ្ញាធរសាធារណៈ ឬគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលសាធារណៈជនម្នាក់ ឬច្រើននាក់ទទួលបានតាមរយៈការធ្វើសំណើទៅកាន់គ្រឹះស្ថាននោះ ។  ព័ត៌មានទាំងនោះរាប់បញ្ចូលនូវព័ត៌មានដែលសាធារណៈជនអាចរកបានតាមរយៈនីតិវិធីដែលបានរៀបចំរួចជាស្រេចដែលធានានូវការចេញផ្សាយស្របគ្នានូវឯកសារសាធារណៈទៅកាន់សាធារណៈជនគ្រប់ស្រទាប់ដែលពាក់ព័ន្ធ និងព័ត៌មាន ឬឯកសារដែលអាចទទួលយកបាន ឬរកបានលុះត្រាតែមានសំណើសុំពីសាធារណៈជន ។

## ចំណាត់ថ្នាក់តម្លាភាពថវិកាអន្តរជាតិ ២០០៨



## ការអង្កេតការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០០៨: របកគំហើញសំខាន់ៗនៃការអង្កេតសកលលោក

ការអង្កេតការផ្សព្វផ្សាយព័ត៌មានថវិកានៅឆ្នាំ ២០០៨ គឺជាការវាយតម្លៃគ្រប់ជ្រុងជ្រោយអំពីតម្លាភាពនៃថវិកានៅក្នុងប្រទេសចំនួន ៨៥ ហើយបានរកឃើញថាតម្លាភាពថវិកានៅជុំវិញពិភពលោកមានសភាពមិនល្អ។ ប្រការនេះផ្តល់ឱកាសឱ្យការចំណាយដែលមានភាពមិនសមស្រប ខ្ជះខ្ជាយ និងពុករលួយ ហើយដោយការកាត់ផ្តាច់សាធារណជនពីដំណើរការសម្រេចចិត្ត គឺកាត់បន្ថយភាពស្របច្បាប់ និងកាត់បន្ថយផលប៉ះពាល់នៃគំនិតផ្តួចផ្តើមប្រឆាំងភាពក្រីក្រ។

ទន្ទឹមនឹងនេះការអង្កេតនេះក៏បង្ហាញផងដែរថាប្រទេសមួយចំនួនបានធ្វើឱ្យប្រសើរឡើងនូវសមិទ្ធិកម្មរបស់ខ្លួនយ៉ាងច្រើនក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ។ ការអង្កេតនេះក៏បានបង្ហាញផងដែរថា រដ្ឋាភិបាលជាច្រើនទៀតអាចលើកកំពស់តម្លាភាពថវិកាយ៉ាងឆាប់រហ័សដោយចំណាយតិចតួចតាមរយៈការផ្តល់លទ្ធភាពឱ្យសាធារណជនអាចទទួលបាននូវព័ត៌មានថវិកាដែលពួកគេបានផលិតសម្រាប់ម្ចាស់ជំនួយរបស់ខ្លួន ឬសម្រាប់ប្រើប្រាស់ផ្ទៃក្នុង។

ការវិភាគការផ្សព្វផ្សាយព័ត៌មានថវិកាដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការអង្កេតដែលវាយតម្លៃថាតើរដ្ឋាភិបាលកណ្តាលផ្តល់ព័ត៌មានថវិកាដល់សាធារណជន និងផ្តល់ឱកាសឱ្យពួកគេចូលរួមនៅក្នុងដំណើរការថវិកាដែរ ឬយ៉ាងណា។ ការអង្កេតនេះក៏ពិនិត្យមើលលទ្ធភាពរបស់ស្ថាប័ននីតិបញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិក្នុងការទាមទារឱ្យរដ្ឋាភិបាលរបស់ខ្លួនទទួលខុសត្រូវផងដែរ។ របកគំហើញនៃការអង្កេតនេះមានមូលដ្ឋានផ្អែកលើទិន្នន័យដែលបានប្រមូលមុនថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០០៧ ហេតុនេះការប្រែប្រួលនានាដែលកើតឡើងក្រោយកាលបរិច្ឆេទនេះមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបកគំហើញនេះទេ។

ដើម្បីសំរួលដល់ការវាស់ស្ទង់ការប្តេជ្ញាជារួមចំពោះតម្លាភាពថវិការបស់ប្រទេសទាំង ៨៥ និងដើម្បីអនុញ្ញាតឱ្យមានការប្រៀបធៀបគ្នារវាងប្រទេស និងប្រទេស ភាពជាដៃគូនៃថវិកាអន្តរជាតិ (IBP) បានបង្កើតសន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា (Open Budget Index -OBI) ចេញពីការអង្កេតស្តីពីការផ្សព្វផ្សាយព័ត៌មានថវិកានៅឆ្នាំ ២០០៨។ ថវិកាគឺជាផែនការរបស់រដ្ឋាភិបាលដែលគ្រោងប្រើប្រាស់ធនធានសាធារណៈដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ តម្លាភាពមានន័យថាប្រជាពលរដ្ឋទាំងឡាយនៃប្រទេសមួយអាចទទួលបាននូវព័ត៌មានអំពីចំនួនទឹកប្រាក់ដែលត្រូវបានវិភាជទៅកាន់ប្រភេទចំណាយផ្សេងៗ មានចំណូលអ្វីខ្លះដែលបានប្រមូល ហើយតើជំនួយបរទេស និងធនធានសាធារណៈដទៃទៀតត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច។ តម្លាភាពគឺជាជំហានទីមួយដែលមានសារៈសំខាន់ក្នុងការទាមទារឱ្យរដ្ឋាភិបាលទទួលខុសត្រូវលើវិធីប្រើប្រាស់ថវិការបស់ប្រជាពលរដ្ឋ។

របកគំហើញមួយនៃរបកគំហើញសំខាន់បំផុតនៃការអង្កេតនេះគឺថា រដ្ឋាភិបាលជាច្រើនផលិតព័ត៌មានថវិកាដែលអនុញ្ញាតឱ្យសាធារណជនចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការថវិកា ប៉ុន្តែមិនផ្សព្វផ្សាយព័ត៌មានទាំងនោះទៅឱ្យសាធារណជនទេ។ ប្រទេស ៥១ ក្នុងចំណោមប្រទេស ៨៥ ដែលបានអង្កេតយ៉ាងហោចណាស់រដ្ឋាភិបាលផលិតឯកសារគន្លឹះមួយច្បាប់ដែលមិនបានផ្សព្វផ្សាយឱ្យសាធារណជនបានដឹង។ ហេតុនេះរដ្ឋាភិបាលអាចបង្កើនតម្លាភាពបានភ្លាម និងត្រូវចំណាយតិចតួចប៉ុណ្ណោះ ដោយគ្រាន់តែផ្សព្វផ្សាយព័ត៌មានថវិកាដែលរដ្ឋាភិបាលបានផលិត។

## ថវិកាដែលបិទជិតបំផុត និងថវិកាដែលមានការផ្សព្វផ្សាយច្រើនបំផុត

ប្រទេសដែលបិទជិតបំផុតគឺប្រទេសដែលធ្វើការផ្សព្វផ្សាយព័ត៌មានថវិកាតិចតួចបំផុតសម្រាប់សាធារណជនដែលរួមមានប្រទេសអារ៉ាប៊ីសាអ៊ូឌីត អាល់ហ្សេរី សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ស៊ូដង់ រវ៉ាន់ដា ហ្គីណេអេក្វាទ័រ និងសៅតូម៉េអេប្រាំងស៊ីប៉េ។

ផ្ទុយទៅវិញ ប្រទេសមួយចំនួនមានតម្លាភាពខ្ពស់ និងអាចអនុញ្ញាតឱ្យសាធារណជនរកព័ត៌មានស្តីពីដំណើរការថវិកាទាំងស្រុងបានយ៉ាងសម្បូណ៌បែប។ យោងតាម OBI បណ្តាប្រទេសដែលមានតម្លាភាពបំផុតរួមមានៈ ចក្រភពអង់គ្លេស អាហ្វ្រិកខាងត្បូង បារាំង ញូវហ្សេលែន និងសហរដ្ឋអាមេរិក។

បណ្តាប្រទេសឆ្នើមទាំងនេះ រួមមានប្រទេសអភិវឌ្ឍន៏ និងកំពុងអភិវឌ្ឍន៏។ ពិន្ទុដ៏ល្អប្រសើរនៃប្រទេសអាហ្វ្រិកខាងត្បូង ស្លូវេនី ស្រីលង្កា និងបូតស្វាណា (ប្រទេសទាំងនេះផ្តល់ព័ត៌មានជាច្រើនទៅកាន់ពលរដ្ឋរបស់ខ្លួន) បង្ហាញថាបណ្តាប្រទេសកំពុងអភិវឌ្ឍន៏អាចធ្វើឱ្យមានតម្លាភាព ប្រសិនបើរដ្ឋាភិបាលរបស់ពួកគេមានសុឆន្ទៈគ្រប់គ្រាន់ក្នុងការផ្សព្វផ្សាយព័ត៌មានថវិកា និងទទួលខុសត្រូវចំពោះពលរដ្ឋរបស់ខ្លួន។

## ការបោះផ្សាយព័ត៌មានថវិកាធ្វើឱ្យមានការផ្លាស់ប្តូរ ~ ឧទាហរណ៍អំពីប្រទេសមួយចំនួន

មានភស្តុតាងបង្ហាញថា នៅពេលដែលពលរដ្ឋមានលទ្ធភាពទទួលបានព័ត៌មាន និងមានឱកាសចូលរួមនៅក្នុងដំណើរការថវិកា ពួកគេមានលទ្ធភាពកែលំអសេចក្តីសម្រេចចិត្តអំពីការចាយវាយថវិកាសាធារណៈ ថាតើត្រូវចំណាយលើអ្វី និងគុណភាពនៃវិធីចំណាយថវិកាជាក់ស្តែង។ ប្រការនេះមានន័យថាការបែងចែកធនធានសាធារណៈដែលមានកំរិត កាន់តែមានសមធម៌ និងកាន់តែមានប្រសិទ្ធភាព។ ឧទាហរណ៏ៈ

- នៅប្រទេសម៉ិចស៊ិចកូអង្គការមិនមែនរដ្ឋាភិបាលមួយឈ្មោះហ៊្វុនដា (Fundar) បានរកឃើញថាថវិកាមិនត្រូវបានវិភាជដើម្បីប្រយុទ្ធនឹងការបាត់បង់ជីវិតក្នុងពេលសំរាលកូនឡើយ ប៉ុន្តែបានតស៊ូមតិប្រកបដោយជោគជ័យដើម្បីឱ្យមានមូលនិធិសម្រាប់សង្គ្រោះបន្ទាន់ក្នុងពេលសម្ភព ពិសេសនៅតំបន់ជនបទ។

- នៅប្រទេសឥណ្ឌា អង្គការកសិករ និងកម្មករខ្នាតតូចឈ្មោះ Mazdoor Kisan Shakarti Sangathan បានផ្គុំព័ត៌មានថវិកាបញ្ចូលគ្នាដើម្បីរកឱ្យឃើញនូវអំពើពុករលួយ ឧទាហរណ៏ឈ្មោះអ្នកស្លាប់ និងឈ្មោះប្រឌិតនៅលើបញ្ជីប្រាក់ខែ និងចំណាយលើកិច្ចការដែលគ្មាននរណាបានធ្វើ។

- តាមការជម្រុញរបស់បណ្តាញបំណុលអ៊ុយហ្គាន់ដាដែលតាមដានចំណាយនៅមូលដ្ឋាន មន្ត្រីអ៊ុយហ្គាន់ដា បានរកឃើញការងារដែលគេអនុវត្តមិនត្រឹមត្រូវតាមការកំណត់ (ក្រោមស្តង់ដារ) លើការងារសាងសង់សាលារៀន និងរកឃើញភស្តុតាងនៃអំពើពុករលួយដែលប្រព្រឹត្តដោយមន្ត្រីមូលដ្ឋាន ហើយដែលបានបដិសេធមិនទូទាត់ឱ្យក្រុមហ៊ុនសំណង់។

- នៅប្រទេសហ្វីលីពីន អង្គការមួយឈ្មោះ ការឃ្លាំមើលរដ្ឋាភិបាល (Government Watch) បានប្រើព័ត៌មានថវិកាចាប់តាំងពីឆ្នាំ២០០០ មកដើម្បីតាមដានការផ្តល់សៀវភៅសិក្សាទៅឱ្យសាលារៀន ការសាងសង់សាលារៀនថ្មីៗ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដទៃទៀតព្រមទាំងតាមដានការចែកមូលនិធិជំនួយគ្រោះមហន្តរាយផងដែរ។ ដោយមានកិច្ចសហការពីក្រុមដទៃទៀតកិច្ចប្រឹងប្រែងរបស់អង្គការនេះបានជួយកាត់បន្ថយចំណាយលើការចែកចាយសៀវភៅសិក្សាជូនរដ្ឋាភិបាលបានយ៉ាងច្រើនព្រមទាំងបានកាត់បន្ថយភាគរយនៃអ្នកម៉ៅការ "ដែលមិនបានអនុវត្តការងារ" ហើយធ្លាប់មានប្រវត្តិមិនផ្តល់សៀវភៅតាមកិច្ចសន្យា។

- កម្មវិធីមួយឈ្មោះ តាមដានការទទួលខុសត្រូវសេវាសាធារណៈ (Public Service Accountability Monitor) នៅខេត្ត Eastern Cape នៃប្រទេសអាហ្វ្រិកខាងត្បូង បានប្រើប្រាស់របាយការណ៍ថវិកា និងប្រើប្រាស់ព័ត៌មានដទៃទៀត ដែលកម្មវិធីនោះបានទទួលធ្វើជាចំណុចចាប់ផ្តើម ដើម្បីតាមដានការប្រើប្រាស់មិនត្រឹមត្រូវ និងភាពមិនប្រក្រតីនៃមូលនិធិ ដែលបានគ្រោងចំណាយសម្រាប់សេវាសំខាន់ៗ ដូចជា អប់រំ ថែទាំសុខភាព និងទឹកស្អាត បានរកឃើញសេវាមានគុណភាព មិនល្អដែលប្រជាជននៅក្នុងខេត្តបានទទួល។

## ការអង្កេតការផ្សព្វផ្សាយព័ត៌មានថវិកាលើមូលដ្ឋាននៃកម្រងសំណួរលំអិត

ការអង្កេតនេះមានសំណួរ ១២៣ ដែលគ្របដណ្តប់លើដំណាក់កាលទាំងបួននៃវដ្តថវិកា គឺដំណាក់កាលរៀបចំថវិកា ដំណាក់ អនុម័ត ដំណាក់កាលអនុវត្តន៍ និងដំណាក់កាលសវនកម្ម ហើយកម្រងសំណួរនេះជួយឱ្យអ្នកស្រាវជ្រាវវាយតម្លៃព័ត៌មានថវិកាដែល គប្បីមាននៅក្នុងដំណាក់កាលនីមួយៗ និងវិធានការចាំបាច់ដទៃទៀតសម្រាប់ការត្រួតពិនិត្យ និងសម្រាប់ការធ្វើសវនកម្មថវិកាឱ្យមាន ប្រសិទ្ធភាព។ សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកាមានមូលដ្ឋានផ្អែកលើការគណនាមធ្យមភាគនៃចម្លើយចំពោះសំណួរចំនួន ៩១ ដែលវាយតម្លៃអំពីលទ្ធភាពទទួលបានព័ត៌មានថវិកាពីសំណាក់សាធារណជន រីឯសំណួរ ៣២ ផ្សេងទៀតនៅលើកម្រងសំណួរនេះ គឺរួមមានព័ត៌មានស្តីពីឱកាសចូលរួមរបស់សាធារណជនក្នុងដំណើរការថវិកា ការត្រួតពិនិត្យរបស់ផ្នែកនីតិបញ្ញត្តិ និងការធ្វើសវនកម្ម ឯករាជ្យ។

នៅក្នុងប្រទេសនីមួយៗ អ្នកស្រាវជ្រាវម្នាក់ ឬក្រុមអ្នកស្រាវជ្រាវដែលមកពីសង្គមស៊ីវិល ហើយដែលមិនចំណុះរដ្ឋាភិបាល និងមិនចំណុះគណបក្សនយោបាយជាអ្នកធ្វើអង្កេត។ អ្នកស្រាវជ្រាវទាំងនោះ ចាំបាច់ត្រូវតែផ្តល់ភស្តុតាងចំពោះចម្លើយរបស់ខ្លួន។ កិច្ចការរបស់អ្នកស្រាវជ្រាវទាំងនោះ ត្រូវបានវិភាគ និងពិនិត្យមើលសារឡើងវិញដោយបុគ្គលិក IBP ដើម្បីផ្ទៀងផ្ទាត់កិច្ចការ ទាំងនោះ ជាមួយព័ត៌មានដែលអាចរកបាន និងបន្ទាប់មកត្រូវពិនិត្យសារជាថ្មីដោយអ្នកជំនាញថវិកាក្នុងស្រុកពីរនាក់ដែលឯករាជ្យ។ ការវាយតម្លៃផ្ទៃក្នុងរបស់សង្គមស៊ីវិលអំពីការផ្សព្វផ្សាយព័ត៌មានថវិកា និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលចំពោះប្រជាជនរបស់ខ្លួន ធ្វើឱ្យការអង្កេតអំពីការផ្សព្វផ្សាយព័ត៌មានថវិកានេះ ខុសពីការសិក្សាផ្សេងទៀតៗលើផ្នែកតម្លាភាពថវិកាដែលពឹងផ្អែកជាចំបងលើការ ស្វ័យរាយការណ៍ដោយរដ្ឋាភិបាលខ្លួនឯង និងការស្រាវជ្រាវដោយអ្នកស្រាវជ្រាវមកពីខាងក្រៅ។

កម្រងសំណួរទាំងស្រុងស្តីពីការផ្សព្វផ្សាយពត៌មានថវិកាពិសេសសម្រាប់កម្ពុជាដែលត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការគណនាពិន្ទុ និង របាយការណ៍នៃការអង្កេតតម្លាភាពថវិកាសកលអាចយកចេញពីគេហទំព័រ: www.openbudgetindex.org ។

## ចំណាត់ថ្នាក់កម្ពុជានៅក្នុងសន្ទស្សន៍ស្តីពីការផ្សព្វផ្សាយព័ត៌មានថវិកា

ដូចដែលបានពន្យល់នៅក្នុងតារាងចំណាត់ថ្នាក់ប្រទេសទាំង ៨៥ កម្ពុជាស្ថិតនៅក្នុងក្រុមប្រទេស ២៥ ដែលមានសន្ទស្សន៍នៃ ការផ្សព្វផ្សាយព័ត៌មានថវិកាដែលផ្តល់ព័ត៌មានថវិកាតិចតួចបំផុតទៅកាន់សាធារណៈជន។ កម្ពុជាមានពិន្ទុសន្ទស្សន៍ ១១% ដូចគ្នានឹង ប្រទេសហុងឌុយរ៉ាស និងសាធារណៈរដ្ឋដូមីនីកែន ហើយមានពិន្ទុសន្ទស្សន៍ខ្ពស់ជាង ១៧ ប្រទេស និង ទាបជាង ៦៥ ប្រទេស។

តារាងចំណាត់ថ្នាក់ខាងក្រោមត្រូវបានចំឡងចេញពីរបាយការណ៍រួមនៃការអង្កេតស្តីពីការផ្សព្វផ្សាយព័ត៌មានថវិកាដែលមាន ក្នុងឯកសារថវិកាសំខាន់ៗទាំង ៨ ជាចំនួនប្រទេសនិមួយៗដែលៈ ធ្វើការផ្សព្វផ្សាយព័ត៌មានថវិកាជាសាធារណៈទៅកាន់ប្រជាពលរដ្ឋ គ្រាន់តែរក្សាឯកសារសម្រាប់តែប្រើប្រាស់ផ្ទៃក្នុង ឬមិនផលិតឯកសារតែម្តង។ ចំពោះឯកសារនីមួយៗរូបញ្ញើមដែលមានពណ៌ផ្កា

ឈ្មោក "☺ "បញ្ជាក់ពីក្រុមប្រទេសដែលកម្ពុជាស្ថិតនៅជាមួយ។ នៅពេលដែលគេចង់ពិនិត្យមើលថាតើឯកសារណាមួយដែលជារួមមានជាសាធារណៈ ឯកសារថវិកាដែលរាជរដ្ឋាភិបាលគួរតែចាប់ផ្តើមធ្វើឱ្យមានជាសាធារណៈគឺ សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ឬ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំរបស់រដ្ឋាភិបាល របាយការណ៍សវនកម្ម របាយការណ៍បុរេថវិកា និង របាយការណ៍អនុវត្តន៍ថវិកាពាក់កណ្តាលឆ្នាំ។

## ការផ្សព្វផ្សាយជាសាធារណៈនៃឯកសារថវិកាសំខាន់ៗតាមក្រុមប្រទេស

ឯកសារថវិកាសំខាន់ៗ




*ចំណាំៈ គ្រប់ប្រទេសទាំងអស់ផលិតឯកសារទាំងពីរនេះ

## អនុសាសន៍

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាគាំទ្រយ៉ាងខ្លាំងក្លាចំពោះគោលគំនិតនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ដែលផ្តោតលើអភិបាលកិច្ចល្អសាធារណៈជាគោល។ យើងខ្ញុំយល់ស្របទាំងស្រុងចំពោះសេចក្តីថ្លែងការណ៍នៅក្នុងយុទ្ធសាស្រ្តចំណុចទី៤២ស្តីពីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែស៊ីជំរៅដែលថាៈ "...រាជរដ្ឋាភិបាលបន្តពង្រឹងប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល..."។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាសុំអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើការឆ្ពោះទៅកាន់តម្លាភាពបន្ថែមទៀតនៅក្នុងការគ្រប់គ្រងធនធានសាធារណៈ និងបង្កើននូវបរិយាកាសមួយដែលយន្តការនៃការទទួលខុសត្រូវអាចត្រូវបានពង្រឹង។ ដូច្នេះវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជាស្នើសុំដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យឯកសារថវិកាដែលមានស្រាប់ក្លាយជាឯកសារដែលអាចរកបានជាសាធារណៈ ដែលការផ្សព្វផ្សាយអាចធ្វើទៅបានដោយចំណាយតិចតួចបំផុត។ ឯកសារទាំងនោះមានដូចខាងក្រោមៈ

- របាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ
- របាយការណ៍ចំណាយថវិកាប្រចាំខែ និងប្រចាំឆ្នាំដែលមានទិន្នន័យលំអិតតាមក្រសួងនីមួយៗ (ដូចជារបាយការណ៍ស្តីពីប្រតិបត្តិការថវិការដ្ឋ ឬ តារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច - TOFE (Table of Financial and

Economic Operations)

- សេចក្តីព្រាងច្បាប់ថវិការបស់ស្ថាប័ននីតិប្រតិបត្តិ (ដូចជា សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ ឬសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ និងគម្រោងសំណើរថវិកាតាមក្រសួងនីមួយៗ)
- របាយការណ៍បុរេថវិកា ឬ សេចក្តីពន្យល់ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំអមសេចក្តីព្រាងច្បាប់ថវិកា (ដូចជា កំណត់បង្ហាញ ឬ/និង សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំ)
- របាយការណ៍អនុវត្តថវិកាពាក់កណ្តាលឆ្នាំ

## អំពីភាពជាដៃគូនៃថវិកាអន្តរជាតិ និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

***ភាពជាដៃគូនៃថវិកាអន្តរជាតិ*** ***(International Budget Partnership-IBP)*** ត្រូវបានបង្កើតឡើងនៅក្នុងមជ្ឈមណ្ឌលអាទិភាពថវិកា និង គោលនយោបាយ ជាអង្គការស្រាវជ្រាវមិនស្វែងរកប្រាក់ចំណេញ មិនបម្រើគណបក្ស មានការិយាល័យនៅវ៉ាស៊ីនតោនឌីស៊ីសហរដ្ឋអាមេរិក ដើម្បីសហការជាមួយអង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍សំដៅវិភាគ តាមដាន និង ធ្វើឱ្យមានឥទ្ធិពលលើដំណើរការថវិកា ស្ថាប័ន និងលទ្ធផលការងាររបស់រដ្ឋាភិបាល។ ភាពជាដៃគូនេះមានគោលបំណងធ្វើឱ្យថវិកាកាន់តែមានលក្ខណៈឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ពលរដ្ឋក្រីក្រ និងអ្នកមានប្រាក់ចំណូលទាបនៅក្នុងសង្គម ហេតុនេះ IBP ធ្វើឱ្យប្រព័ន្ធទាំងនេះ កាន់តែមានតម្លាភាព និងមានការទទួលខុសត្រូវចំពោះសាធារណជន។

ចំពោះព័ត៌មានបន្ថែមស្តីពី IBP សូមចូលគេហទំព័រ: www.internationalbudget.org ។

***វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*** ***(The NGO Forum on Cambodia-NGOF)*** ជាអង្គការសមាជិកភាពសម្រាប់អង្គការ មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលធ្វើការនៅកម្ពុជា។ អាណត្តិនៃអង្គការនេះគឺដើម្បីចែករំលែកព័ត៌មាន ជជែកដេញដោល និងតស៊ូមតិលើបញ្ហាអាទិភាពដែលប៉ះពាល់ដល់ការអភិវឌ្ឍរបស់កម្ពុជា។ គម្រោងថវិកាជាតិរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជាបានទទួលការឧបត្ថម្ភគាំទ្រពីភាពជាដៃគូនៃថវិកាអន្តរជាតិ។

ចំពោះព័ត៌មានបន្ថែមស្តីពី NGOF សូមចូលគេហទំព័រ: www.ngoforum.org.kh ។

*ការស្រាវជ្រាវដើម្បីបំពេញកម្រងសំណួរស្តីពីការផ្សព្វផ្សាយព័ត៌មានថវិកាសំរាប់កម្ពុជាគិតត្រឹមថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០០៧ អនុវត្តដោយ:*
*អ៊ូ ស៊ីវហួច និង Gijs Koop*
*វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*
*លេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ ទួលទំពូង ១ ប្រអប់សំបុត្រលេខ ២២៩៥ ភ្នំពេញ ៣ កម្ពុជា*
*ទូរស័ព្ទ: (៨៥៥) ២៣ ២១៤ ៤២៩*
*គេហទំព័រ: www.ngoforum.org.kh*

*បោះពុម្ពដោយ: គម្រោងថវិកាជាតិ នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា*
*ចំពោះព័ត៌មានបន្ថែមពាក់ព័ន្ធនឹងព្រឹត្តិបត្រនេះសូមទំនាក់ទំនងតាមអាសយដ្ឋានខាងលើ ឬតាមអ៊ីម៉ែល:* ngoforum@ngoforum.org.kh ។